# គណបក្ស សិទ្ធិមនុស្ស
# HUMAN RIGHTS PARTY

បំរើ ការពារ កសាង

លេខ ០០០៩/១០ គ.ស.ម

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២២ ខែមករា ឆ្នាំ២០១០

## សេចក្តីថ្លែងការណ៍

ថ្ងៃទី២២ ខែមករា ឆ្នាំ២០១០ គឺជាខួបគំរប់៦ឆ្នាំដែលឃាតករកំណាចបានបាញ់សម្លាប់លោក **ជា វិជ្ជា** ប្រធានសហជីពសេរីកម្មករដ៏មានប្រជាប្រិយភាព នៅពេលលោកកំពុងតែអានកាសែតនៅក្រោយវត្តលង្កា ។ ក្រោយមកប៉ុន្មានថ្ងៃសមត្ថកិច្ចបានចាប់មនុស្ស២នាក់ដែលគេចាត់ទុកជាឃាតករសម្លាប់លោក **ជា វិជ្ជា** គឺ **សុក សំអឿន** និង **បឹន សំណាង** ហើយជនរងគ្រោះទាំង២ត្រូវតុលាការកាត់ទោសដាក់ពន្ធនាគារអស់ជិត៥ឆ្នាំ ទោះបីអង្គការជាតិ និងអន្តរជាតិនានាបានអះអាងថាអ្នកទាំងពីរពុំមែនជាឃាតករក៏ដោយ ។ រយៈពេល៦ឆ្នាំហើយដែលឃាតករពុំត្រូវបានសមត្ថកិច្ចចាប់ខ្លួនយកមកផ្តន្ទាទោសសោះ ហើយសមត្ថកិច្ចចេះតែបន្តអះអាងថាខ្លួនកំពុងតែតាមរកឃាតករនោះហើយ ។ ពាក្យនេះយើង គណបក្សសិទ្ធិមនុស្ស ពិតជាពិបាកជឿណាស់ព្រោះមានករណីជាច្រើនដែលឃាតកររួចខ្លួន ហើយសមត្ថកិច្ចពោលតែពាក្យដដែលដូចគ្នានេះដែរ ។

**គណបក្សសិទ្ធិមនុស្ស** ដែលប្រកាន់ជំហរអហិង្សា ក្នុងការដោះស្រាយបញ្ហាជាតិ ថ្កោលទោសយ៉ាងខ្លាំងក្លាបំផុតចំពោះអំពើហិង្សាគ្រប់រូបភាពទាំងអស់ ហើយទទូចដល់សមត្ថកិច្ចរាជរដ្ឋាភិបាលតាមចាប់ឃាតករទាំងអស់យកមកផ្តន្ទាទោសតាមផ្លូវច្បាប់ ទើបព្រះរាជាណាចក្រកម្ពុជាអាចទទួលបានសន្តិភាពពិតប្រាកដ ព្រោះថាកាលណានិទណ្ឌភាពនៅតែបន្តកើតមាននៅកម្ពុជានោះសុខសន្តិភាពពុំអាចកើតឡើងបានឡើយ ។

គណបក្ស សិទ្ធិមនុស្ស H.R.P HUMAN RIGHTS PARTY

*សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង*
*ទូរស័ព្ទលេខ ៖ ០១៦ ៨៣៥ ១០៦*

Address: #72-74, Street 598, Sangkat Boeung Kok 2, Khan Tuol Kok, Phnom Penh, Cambodia.
Tel: (+855) 17 303 900 / 023 884 649 | Email: hrpcambodia@yahoo.com | Website: www.hrpcambodia.info